**ឧបសម្ព័ន្ធទី៣៖ ឧបនិស្ស័យ និងគុណសម្បត្តិស័ក្តិសមតាមមុខតំណែងនីមួយៗរបស់រដ្ឋបាលក្រុង**

**ភ្ជាប់នឹងអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង**

| មុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណៈសម្បត្តិស័ក្តិសម |
|---|---|---|
| នាយករងរដ្ឋបាលក្រុង | ឋានន្តរស័ក្តិទី២<br>នៃក្របខ័ណ្ឌប្រភេទ ខ | – មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ ឬមានអតីតភាពការងារយ៉ាងតិច០៣ឆ្នាំ បើបេក្ខជនមានប្រភេទក្របខ័ណ្ឌ "ក"<br>– មានបទពិសោធន៍ និងសមត្ថភាពក្នុងការដឹកនាំ និងគ្រប់គ្រង<br>– មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>– មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>– មានសាមគ្គីភាពល្អ និងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>– មានសុខភាពល្អ។ |
| ប្រធានការិយាល័យ | ឋានន្តរស័ក្តិទី២<br>នៃក្របខ័ណ្ឌប្រភេទ ខ | – មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ ឬមានអតីតភាពការងារយ៉ាងតិច០៣ឆ្នាំ បើបេក្ខជនមានប្រភេទក្របខ័ណ្ឌ "ក"<br>– មានបទពិសោធន៍ និងសមត្ថភាពក្នុងការដឹកនាំ និងគ្រប់គ្រង<br>– មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>– មានចំណេះដឹង និងបទពិសោធន៍លើការងារជំនាញពាក់ព័ន្ធនឹងមុខងាររបស់ការិយាល័យដែលត្រូវស្នើតែងតាំង<br>– មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>– មានសាមគ្គីភាពល្អ និងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>– មានសុខភាពល្អ។ |

| | | |
|---|---|---|
| ប្រធានអង្គភាពលទ្ធកម្ម | ឋានន្តរស័ក្តិទី២<br>នៃក្របខ័ណ្ឌប្រភេទ ខ | – មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ ឬមានអតីតភាពការងារយ៉ាងតិច០៣ឆ្នាំ បើបេក្ខជនមានប្រភេទក្របខ័ណ្ឌ "ក"<br>– មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្ររងផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ<br>– មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុយ៉ាងតិច ០៣ឆ្នាំ<br>– ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>– មានសាមគ្គីភាពល្អ និងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>– មានសុខភាពល្អ។ |
| អនុប្រធានការិយាល័យ ឬ<br>អនុប្រធានអង្គភាពលទ្ធកម្ម | ឋានន្តរស័ក្តិទី៣<br>នៃក្របខ័ណ្ឌប្រភេទ ខ | – មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ ឬមានអតីតភាពការងារយ៉ាងតិច០២ឆ្នាំ បើបេក្ខជនមានប្រភេទក្របខ័ណ្ឌ "ក"<br>– មានបទពិសោធន៍ និងសមត្ថភាពក្នុងការងារអនុវត្តការងារ<br>– មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>– មានចំណេះដឹង និងបទពិសោធន៍លើការងារជំនាញពាក់ព័ន្ធនឹងមុខងាររបស់ការិយាល័យ ឬអង្គភាពដែលត្រូវស្នើតែងតាំង<br>– មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>– មានសាមគ្គីភាពល្អ និងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>– មានសុខភាពល្អ។ |